ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០២៣.៩៦០.ធ.ជ.ក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទស្ក្ករ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្លាស់ប្តូរយន្តការទូទាត់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ឥណប្រតិទាន ៧ថ្ងៃ

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថាន-មីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានឹងធ្វើការកែសម្រួលថ្ងៃទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ឥណប្រតិទាន ៧ថ្ងៃ ពីការទូទាត់ (T+2) មកជាការទូទាត់នៅក្នុងថ្ងៃដេញថ្លៃ (T+0) វិញ ដែលនឹងអនុវត្តចាប់ពីថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ នេះតទៅ។

ចំពោះប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ ធនាគារជាតិនៃកម្ពុជា នឹងរក្សាទុកយន្តការទូទាត់ (T+2) នៅដដែល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមអនុវត្ត តាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ២៣០ ៦៧៥ EXT. ១០៤៨
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨

សារអេឡិចត្រូនិក : lpco_info@nbc.gov.kh

បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA